# ភ្នំឱរ៉ាល់ A1 & A2



**ខេត្ត** : ពោធិសាត់ កំពង់ស្ពឺ និង កំពង់ឆ្នាំង

**ស្រុក** : ក្រវាញ ឱរ៉ាល់ និង ទឹកផុស

**ផ្ទៃដី ( ហិកតា)** : ៥០.០៨៥

**រយៈកំពស់ ( ម៉ែត្រ)** : ៣៨០ ដល់ ១.៧៥៦

**កូអរដោនេចំណុចកណ្ដាល** : ១២$^{0}$០៣' ជ ១០៤$^{0}$០៩' ក

**ការពិពណ៌នាទីកន្លែង**

តំបន់ IBA នេះ ស្ថិតនៅក្នុងដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ក្នុងជួរភ្នំក្រវាញ ។ តំបន់ IBA នេះ រួមមានតំបន់ព្រៃស្រោង និង ព្រៃពាក់កណ្ដាលស្រោង ដែលមានរយៈកំពស់លើសពី៤០០ម៉ែត្រធៀបនឹងនីវ៉ូសមុទ្រ ដែលគេគិតថា ជាកំរិតរយៈកំពស់សមស្រប ចំពោះប្រភេទក្រួចសំពៅ ។ តាមលក្ខណៈសណ្ឋានដី តំបន់នេះគ្របដណ្ដប់លើសលប់ដោយភ្នំឱរ៉ាល់មានកំពស់ប្រហែល១.៨១៣ ម៉ែត្រ ដែលជាភ្នំខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា ។ នៅរយៈកំពស់ក្រោម១.២០០ម៉ែត្រ តំបន់នេះគ្របដណ្ដប់លើសលប់ដោយ ព្រៃស្រោង ហើយនៅរយៈកំពស់រវាង១.២០០ម៉ែត្រ និង ១.៥០០ម៉ែត្រ គ្របដណ្ដប់ដោយព្រៃស្រោងតំបន់ភ្នំ រីឯកំពស់លើសពី ១.៥០០ម៉ែត្រ គ្របដណ្ដប់ដោយព្រៃស្រោងតំបន់ភ្នំផ្នែកខាងលើ ។ តំបន់ IBA នេះទ្រទ្រង់សត្វពីរប្រភេទដែលត្រូវបានរកឃើញ តែក្នុងតំបន់ជួរភ្នំប្រទេសកម្ពុជា និង ប្រទេសថៃប៉ុណ្ណោះ រួមមានក្រួចសំពៅ និង ចកវិកកម្ពុជា ។

**ប្រភេទសត្វស្លាបសំខាន់ៗ**

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| កេងកងធំ | Great Hornbill | *Buceros bicornis* | A1 | |
| ក្រួចសំពៅ | Chestnut-headed Partridge | *Arborophila cambodiana* | A1 | A2 |
| ចកវិកកម្ពុជា | Cambodian Laughingthrush | *Garrulax ferrarius* | | A2 |
| ស្ដេចកូលិត | Siamese Fireback | *Lophura diardi* | A1 | |

**ប្រភេទសត្វប្រមូលផ្ដុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាប១២ប្រភេទរស់នៅក្នុងប្រភេទព្រៃតំបន់ភ្នំខ្ពស់៧ និង បួនប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង (សូមមើល តារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក**

រញ៉ីប្រផេះ ស្វាត្រោស ស្វាព្រាម និង ទោចម្កុដ ។

**ដំរី និង ពពួកក្រចកជំពាមទទួលរងការគំរាមកំហែងពិភពលោក**

ដំរី និង ខ្ទីង ។

**ការគំរាមកំហែងលើជីវៈចំរុះ**

សំពាធការបរបាញ់សត្វស្លាបនៅក្នុងតំបន់នេះកើតឡើងតិចតួច ហើយកើតមានច្រើនដោយសកម្មភាពដាក់អន្ទាក់លើពពួកសត្វស្លាបដើររកស៊ីលើដី ដូចជាក្រួចសំពៅ មាន់ទោពណ៌ប្រាក់ និង សត្វយំសម្រាប់យកមកបរិភោគក្នុងគ្រួសារ ។ ការដាក់អន្ទាក់ភាគច្រើនធ្វើឡើងដោយអ្នករុករកខ្លឹមច័ន្ទ ។ ការគំរាមកំហែងមួយទៀត គឺការកាប់ព្រៃឈើ ដែលនាំឱ្យមានការថយចុះ និង បាត់បង់ប្រភេទទីជំរក ។ ការគំរាមកំហែងនេះមានកំរិតទាបនាពេលបច្ចុប្បន្ន ចាប់តាំងពីការធ្វើពាណិជ្ជកម្មព្រៃឈើទ្រង់ទ្រាយធំឈប់កើតមានឡើងនៅក្នុងតំបន់នេះ ហើយការកាប់ព្រៃឈើខុសច្បាប់ទ្រង់ទ្រាយតូចៗ ក៏មានការថយចុះផងដែរ ។

### អនុសាសន៍

ការអនុវត្តន៍ច្បាប់ និង ការល្បាតរបស់សត្តរក្សនៅពេលបច្ចុប្បន្ននៅក្នុងតំបន់ដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ផ្តោតលើសកម្មភាពខុសច្បាប់ទាំងឡាយ (ការប្រមាញ់ និង ការកាប់ព្រៃឈើ) គួរតែបន្តអនុវត្ត និង ពង្រីកសកម្មភាពនៅតាមតំបន់សំខាន់ៗទាំងអស់ ។

### ឯកសារយោង

Swan, S. R. and Long, B. (2002) Birds. In J. C. Daltry ed. *Social and ecological surveys of Phnom Aural Wildlife Sanctuary, Cardamom mountains, Cambodia*. Phnom Penh: Fauna & Flora International Cambodia Program me.